EFF'S SURVEILLANCE SELF-DEFENSE

# វិធីប្រើប្រាស់កម្មវិធីស៊ីហ្គណល សម្រាប់ ANDROID

https://ssd.eff.org/en/about-surveillance-self-defense

LOCALIZATION LAB

***សេចក្ដីណែនាំនេះត្រូវបានសម្រួលពីការការពារខ្លួនពីការឃ្លាំមើលរបស់មូលនិធិ Electronic Frontier Foundation៖**
**https://ssd.eff.org/en/module/how-use-signal-android**

ស៊ីហ្គណាល ជាកម្មវិធីឥតគិតថ្លៃ និងបើកទូលាយ សម្រាប់ Android iOS និងកុំព្យូទ័រដែលប្រើប្រាស់កូដនីយកម្មទាំងសងខាង អនុញ្ញាតឲ្យអ្នកប្រើប្រាស់ផ្ញើសារជាអក្សរ រូបភាព សំឡេងនិងវីដេអូ និងមានការសន្ទនាសម្ងាត់រវាងអ្នកប្រើប្រាស់ស៊ីហ្គណាល។ ទោះបីជាស៊ីហ្គណាលប្រើប្រាស់លេខទូរស័ព្ទសម្រាប់ទាក់ទង ការហៅនិងផ្ញើសារសម្ងាត់ប្រើប្រាស់ការតភ្ជាប់ទិន្នន័យ ដូច្នេះភាគីទាំងសងខាង ត្រូវមានការប្រើប្រាស់អ៊ីនធឺណេត នៅក្នុងទូរស័ព្ទរបស់គេ។ ដោយហេតុផលនេះហើយ អ្នកប្រើប្រាស់ស៊ីហ្គណាលមិនត្រូវបានបង់ថ្លៃលើសារ SMS និង MMS សម្រាប់ប្រភេទសន្ទនាទាំងនេះទេ។ នៅលើ Android ស៊ីហ្គណាលអាចជំនួសកម្មវិធីបើកសារ លំនាំដើម ដូចនេះស៊ីហ្គណាល នៅតែអាចផ្ញើសារSMS មិនសម្ងាត់។ សារSMS មិនសម្ងាត់ ប្រើលេខទូរស័ព្ទរបស់អ្នក និងអាចត្រូវបង់ថ្លៃតាមគម្រោងរបស់អ្នក។

ទីតាំងសម្រាប់ទាញយក ៖ អ្នកប្រើប្រាស់អាចទាញយកកម្មវិធីបានពី Google Play Store ។
លក្ខខណ្ឌតម្រូវតាមប្រព័ន្ធ៖ ប្រព័ន្ធ Android ជំនាន់ ៤ ឡើងទៅ
ជំនាន់ដែលប្រើប្រាស់ជាគំរូក្នុងសេចក្ដីណែនាំនេះគឺ 4.18.3

អជ្ញាប័ណ្ណ៖ GPLv3
ការអានបន្ថែម៖

- https://signal.org/
- https://support.signal.org/
- https://signal.org/blog/

កំរិត៖
អ្នកប្រើប្រាស់ពីកំរិតដំបូងទៅធម្យម
ថេរវេលាសម្រាប់តំឡើង៖
ពី ១៥ ទៅ ២០ នាទី
ការកែសម្រួលចុងក្រោយ៖
ថ្ងៃទី ៩ ខែ ៥ ឆ្នាំ ២០១៨

# ការតំឡើង ស៊ីហ្គណាល លើទូរស័ព្ទAndroid

## ជំហានទី ១ ៖ ទាញយក និងតំឡើងកម្មវិធី ស៊ីហ្គណាល

នៅលើប្រព័ន្ធដំណើរការ Android សូមលោកអ្នកចូលទៅកាន់ Google Play Store ហើយស្វែងរកពាក្យ Signal ។ បន្ទាប់មកលោកអ្នកចុចពាក្យ Signal Private Messenger ហើយធ្វើការដំឡើងតាមការណែនាំ

បន្ទាប់ពីដំឡើង Signal រួច ចុចលើ “បើក” ដើម្បីចាប់ផ្ដើមដំណើរការកម្មវិធី

## ជំហានទី២៖ ចុះឈ្មោះ និងផ្ទៀងផ្ទាត់លេខទូរស័ព្ទ របស់អ្នក

នៅពេលអ្នកបានបើកកម្មវិធី ស៊ីហ្គណាល អាចនឹងទាមទារការចូលប្រើប្រាស់បញ្ជីទំនាក់ទំនង និងឯកសារមេឌា។




អ្នកអាចចុច “បន្ត” និងស៊ីហ្គណលនឹងនាំអ្នកទៅកាន់ការទាមទារសិទ្ធិប្រើប្រាស់មួយជំហានម្តងៗ។ បើអ្នកបដិសេធនឹងការស្នើសុំនេះ ស៊ីហ្គណលអាចនឹងសួរម្តងទៀត នៅពេលក្រោយ។

ឥលូវអ្នកនឹងឃើញ អេក្រង់ដូចខាងក្រោម។ បញ្ចូលលេខទូរស័ព្ទរបស់អ្នក និងចុច “ចុះឈ្មោះ”។



នៅពេលនេះ អ្នកនឹងត្រូវបានសួរ ដើម្បីអនុញ្ញាតឲ្យ ស៊ីហ្គណលបង្ហាញសារ SMS។ នេះអនុញ្ញាតឲ្យស៊ីហ្គណល់ផ្ទៀងផ្ទាត់លេខទូរស័ព្ទងាយស្រួលជាងមុន។ អ្នកអាចបដិសេធការស្នើសុំនេះ ដោយចុច “បន្ត” និង “បដិសេធ” ឬអនុញ្ញាតវាំឲ្យ ដោយចុច “បន្ត” និង“អនុញ្ញាត” អ្នកអាចបញ្ចប់ការដំឡើងដោយបញ្ចូលលេខកូដ៦ខ្ទង់ ដែលនឹងផ្ញើជូនអ្នកតាមសារ SMS មួយ។




នៅពេលអ្នកបញ្ចូល ឬអនុញ្ញាតស៊ីហ្គណល ឲ្យអានកូដសារ SMSរបស់អ្នក ការចុះឈ្មោះរបស់អ្នកនឹងត្រូវបញ្ចប់។






## ជំហានទី៣៖ ជ្រើសរើសឈ្មោះ និងរូបតំណាង

រូបភាពតំណាងនិងទម្រង់ឈ្មោះដែលអ្នកជ្រើសរើសនឹងត្រូវបានបង្ហាញបញ្ជីទំនាក់ទំនងដែលអ្នកបានរក្សាទុកនៅក្នុងសៀវភៅអាសយដ្ឋានរបស់អ្នក នៅពេលដែលអ្នកចាប់ផ្តើមសន្ទនាថ្មី និងនៅពេលដែលអ្នកអនុញ្ញាតឲ្យអ្នកទំនាក់ទំនង ឬក្រុមជាក់លាក់មើលព័ត៌មាននេះ។ បញ្ចូលព័ត៌មានទាក់ទងផ្សេងៗនៅក្នុងជំហាននេះ និង ចុះ “បញ្ចប់” ឬក៏ រំលងជំហាននេះដោយចុះ “កំណត់ពេលក្រោយ” នៅខាងក្រោម។



បន្ទាប់ពីដំណើរការនេះបានបំពេញ អ្នកនឹងឃើញដូចអេក្រង់ខាងក្រោម




គួរចំណាំថាប្រសិនបើអ្នកសម្រេចចិត្តប្រើប្រាស់ស៊ីហ្គណលជាកម្មវិធីសារ SMS លំនាំដើម សារដែលបានផ្ញើទៅកាន់លេខទំនាក់ទំនង ដែលមិនមានស៊ីហ្គណល (ទោះបីអ្នកផ្ញើក្នុងស៊ីហ្គណលក៏ដោយ) នឹងមិនសម្ងាត់ទេ។

## ការប្រើប្រាស់ស៊ីហ្គណល

ដើម្បីអាចប្រើប្រាស់ស៊ីហ្គណលបាន អ្នកដែលទាក់ទងជាមួយអ្នកត្រូវតែដំឡើងស៊ីហ្គណលដែរ។ ប្រសិនបើអ្នកព្យាយាមផ្ញើសារទៅអ្នកដែលប្រើប្រាស់ស៊ីហ្គណល ហើយពួកគេមិនបានដំឡើងស៊ីហ្គណល នោះវានឹងផ្ញើសារធម្មតាមួយដោយមិនមែនកូដនីយកម្មសារ។ បើអ្នកព្យាយាមហៅទៅលេខនរណាម្នាក់ វានឹងប្តូរទៅជាការហៅចេញធម្មតា។

ស៊ីហ្គណលផ្តល់ឲ្យអ្នកនូវបញ្ជីរបស់អ្នកប្រើប្រាស់ផ្សេងទៀតដែលអ្នករក្សាលេខទុកក្នុងទូរសព្ទរបស់អ្នក។ ទិន្នន័យតំណាងឲ្យលេខទូរសព្ទនៅក្នុងបញ្ជីឈ្មោះរបស់អ្នកត្រូវបានបញ្ជូនទៅក្នុងបណ្តាញស៊ីហ្គណល ប៉ុន្តែទិន្នន័យនេះគឺត្រូវបានលុបយ៉ាងបន្ទាន់។

### របៀបផ្ញើសារសម្ងាត់

ចូរចំណាំថា Open Whisper Systems អ្នកបង្កើតស៊ីហ្គណល ប្រើប្រាស់ធនធានរបស់ក្រុមហ៊ុនផ្សេងទៀតដើម្បីផ្ញើសារទៅរំលឹកអ្នកដែលប្រើប្រាស់ នៅពេលដែលពួកគេទទួលបានសារថ្មី។ ពួកគេប្រើប្រាស់ Google លើ Android និង Apple លើ iPhone ដែលមានន័យថាព័ត៌មានអ្នកដែលទទួលសារ និងនៅពេលដែលពួកគេបានទទួលប្រហែលជាលេចធ្លាយទៅក្រុមហ៊ុនទាំងនោះ។

ដើម្បីចាប់ផ្តើម ចុចរូបតំណាងខ្មៅដៃនៅក្រោមជ្រុងខាងស្តាំនៃអេក្រង់។




អ្នកនឹងឃើញបញ្ជីឈ្មោះអ្នកប្រើប្រាស់ស៊ីណ្គលទាំងអស់នៅក្នុងបណ្ដាញទំនាក់ទំនងរបស់អ្នក។



អ្នកក៏អាចបញ្ចូលលេខទូរស័ព្ទអ្នកប្រើប្រាស់ស៊ីណ្គុលដែលមិនមាននៅក្នុងការទំនាក់ទំនងរបស់អ្នក។ នៅពេលអ្នកជ្រើសរើសអ្នកត្រូវទំនាក់ទង អ្នកនឹងត្រូវនាំទៅអេក្រង់ផ្ញើសាជាអក្សរសម្រាប់ការទាក់ទងរបស់អ្នក។ ចំណាំ អ្នកប្រើប្រាស់ស៊ីហ្គណាល់ អ្នកនឹងឃើញអក្សរ "សារស៊ីហ្គណាល" នេះមានន័យថាសារនឹងត្រូវបានបំលែងជាសម្ងាត់។ នៅលើអេក្រង់នេះ រូបតំណាង "ទូរស័ព្ទ" នៅផ្នែកលើខាងស្តាំ នឹងបង្ហាញថាអ្នកអាចធ្វើការហៅជាសំឡេងសម្ងាត់ដោយប្រើប្រាស់ស៊ីណ្គុលផងដែរ។ សម្រាប់អេក្រង់នេះ អ្នកអាចផ្ញើសាជាអក្សរ រូបភាព សំឡេង វីដេអូ និងឯកសារទាំងសងខាងជាការសម្ងាត់។




សម្រាប់អ្នកប្រើប្រាស់ដែលមិនបានដំឡើងស៊ីហ្គណាល អ្នកនឹងឃើញសារ "សារគ្មានសុវត្ថិភាព" ដែលមានន័យថាសារនឹងមិនមានការសម្ងាត់។ នៅលើអេក្រង់ទូរសព្ទដែលមាន រូបតំណាងជ្រុងស្តាំផ្នែកខាងលើ នៃអេក្រង់ទូរសព្ទនឹងចាប់ផ្តើមការទូរសព្ទធម្មតាដោយមិនសម្ងាត់។



## របៀបចាប់ផ្តើមការសន្ទនាសម្ងាត់

ដើម្បីចាប់ផ្តើមការសន្ទនាតាមទូរស័ព្ទសំងាត់ជាមួយដៃគូរសន្ទនារបស់លោកអ្នក សូមជ្រើសរើសឈ្មោះរបស់ដៃគូរសន្ទនារបស់អ្នក បន្ទាប់មកចុចលើប៊ូតុងដែលមានសញ្ញាទូរស័ព្ទ។ បន្ទាប់មកអ្នកនឹងដឹងថាដៃគូរសន្ទនាម្ខាងទៀតយល់ព្រមទទួលយកការសន្ទនាតាមប្រព័ន្ធ ស៊ីហ្គណល ប្រសិនបើជាអ្នកបានឃើញសញ្ញាទូរស័ព្ទ និងសោរតូចមួយដែលនៅក្បែរគ្នានៅលើទូរស័ព្ទរបស់លោកអ្នក ។




នៅពេលដែលអ្នកបានហៅទូរស័ព្ទចេញ កិច្ចសន្ទនារបស់អ្នកជាការសំងាត់។

## របៀបបង្កើតការសន្ទនាតាមវិឌីអូសំងាត់

ដើម្បីបង្កើតការសន្ទនាតាមការហៅទូរស័ព្ទតាមវីឌីអូ អ្នកគ្រាន់តែធ្វើការហៅទៅកាន់អ្នកណាម្នាក់ដូចបានណែននាំខាងលើ បន្ទាប់អ្នកត្រូវយល់ព្រមអោយប្រព័ន្ធ ស៊ីហ្គណល ប្រើប្រាស់កាម៉េរ៉ា និងម៉ៃក្រូហ្វូនរបស់ទូរស័ព្ទរប័ស់លោកអ្នក ។




ជំហានបន្ទាប់ សូមចុចលើរូបតំណាងនៃការហៅទូរស័ព្ទតាមវីឌីអូ




នៅពេលដែលអ្នកអាចឃើញរូបជាទំរង់វីឌីអូរបស់ដៃគូរសន្ទនារបស់អ្នកនោះ ដៃគូររបស់លអ្នកក៏អាចមើលឃើញរូបអ្នកក្នុងពេលជំណាលគ្នាផងដែរ។




## របៀបចាប់ផ្តើមការជជែកសម្ងាត់ជាក្រុម

អ្នកអាចផ្ញើសារសម្ងាត់តាមក្រុម ដោយចុចរូបផ្ញើ នៅជ្រុងស្តាំដៃនៃអេក្រង់ បន្ទាប់មក ចុចលើរូបចុចៗ៣ និងជ្រើសរើស “ក្រុំមថ្មី”។






នៅអេក្រង់ខាងក្រោម អ្នកនឹងអាចដាក់ឈ្មោះក្រុម និងបន្ថែមអ្នកចូលរួមបាន។






បន្ទាប់ពីបន្ថែមអ្នកចូលរួម អ្នកអាចចុចលើ ប្រអប់ខាងលើផ្នែកខាងឆ្វេងនៃអេក្រង់។ នេះអាចចាប់ផ្តើមការជជែកជាក្រុម។



បើអ្នកចង់ ផ្លាស់ប្តូរឈ្មោះក្រុម រូបតំណាង ឬបន្ថែមអ្នកចូលរួម វាអាចធ្វើបានតាមអេក្រង់ជជែកតាមក្រុម ដោយចុចលើរូបចុចៗ៣ ខាងលើផ្នែកខាងស្តាំនៃអេក្រង់ ហើយជ្រើសរើស “កែប្រែក្រុម”។

## បិទសំឡេងការសន្ទនា

ពេលខ្លះការសន្ទនាអាចរំខាន។
លក្ខណៈពិសេសមួយដែលមានប្រយោជន៍សម្រាប់ការជជែកជាក្រុមត្រូវបានផ្លាស់ប្តូរការជូនដំណឹងដូច្នេះអ្នកមិនឃើញការជូនដំណឹងថ្មីរាល់ពេលសារថ្មីត្រូវបានទេ។
នេះអាចធ្វើបានពីផ្ទាំងជជែកជាក្រុមដោយចុចរូបតំណាងលើឈ្មោះក្រុម និងជ្រើសរើស "ការជូនដំណឹងស្ងាត់ៗ " ។
បន្ទាប់មកអ្នកអាចជ្រើសរយៈពេលដែលអ្នកចង់ឱ្យបិទសកម្ម។
នេះអាចត្រូវបានអនុវត្តចំពោះការសន្ទនាបុគ្គលផងដែរ បើអ្នកចង់។

## វិធីផ្ទៀងផ្ទាត់លេខទំនាក់ទំនងរបស់អ្នក

នៅក្នុងចំណុចនេះ អ្នកអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបុគ្គលដែលអ្នកមានទំនាក់ទំនងជាមួយដើម្បីប្រាកដថាកូដនីយកម្មរបស់ពួកគេត្រឹមត្រូវ មិនត្រូវបានក្លែងបន្លំពីអ្នកដទៃ នៅពេលដែលអ្នកទាញយកកម្មវិធីនេះ (ដំណើរការនេះហៅថាការផ្ទៀងផ្ទាត់ កូដនីយកម្ម)។ ការផ្ទៀងផ្ទាត់គឺជាដំណើរការមួយដែលអ្នកត្រូវធ្វើចំពោះមុខម្ចាស់គណនី។

ដំបូង បើកអេក្រង់ដែលអ្នកផ្ញើសារទៅលេខទំនាក់ទំនងរបស់អ្នក ដូចដែលបានរៀបរាប់ខាងលើ។ នៅលើកអេក្រង់នេះ ចុចលើរូបតំណាង (រូបសញ្ញា ចុចៗ៣ នៅជ្រុងខាងលើស្តាំដៃនៃអេក្រង់) ហើយជ្រើសរើសយក “ការកំណត់ការសន្ទនា”។



លើអេក្រង់ខាងក្រោមនេះ ចុចលើ “ពិនិត្យលេខកូដសុវត្ថិភាព”




ឥឡូវនេះអ្នកដាក់អេក្រង់ដែលបង្ហាញ QR កូដ និងលេខសុវត្ថិភាព។ កូដសំខាន់នេះនឹងមានតែមួយគត់រាល់ការទំនាក់ទំនងផ្សេងៗដែលអ្នកសន្ទ



ចូលទៅកាន់កម្មវិធីរបស់អ្នក អ្នកអាចចុចលើ QR កូដរបស់អ្នក ដែលប្រើប្រាស់ដោយ ម៉ាស៊ីនថតដើម្បីថតយក QR កូដដែលមានលើអេក្រង់ទំនាក់ទំនាក់ទំនងរបស់អ្នក។ តម្រង់ ម៉ាស៊ីនថតរបស់អ្នកឲ្យត្រូវនឹងQR កូដ៖




សង្ឃឹមថា កាមេរ៉ារបស់អ្នកនឹងអាចស្កេនកូដ QR និងបង្ហាញសញ្ញាធីកដូចនេះ៖



នេះបង្ហាញថាអ្នកបានផ្ទៀងផ្ទាត់ការទាក់ទងរបស់អ្នកបានជោគជ័យ។អ្នកគួរចុចរំកិលបន្ទាប់សម្រាប់ “ផ្ទៀងផ្ទាត់” ដើម្បីឲ្យកម្មវិធីចងចាំថាទំនាក់ទំនងរបស់អ្នកបានត្រូវផ្ទៀងផ្ទាត់រួចហើយ។ ប្រសិនបើអ្នកឃើញអេក្រង់បែបនេះ មានន័យថា អ្វីមួយខុសប្រក្រតី៖




អ្នកប្រហែលជាត្រូវជៀសវាងការពិភាក្សាប្រធានបទរសើបរហូតដល់អ្នកបានផ្ទៀងផ្ទាត់សោរសំងាត់ជាមួយមនុស្សនោះ។

ចំណាំសម្រាប់អ្នកប្រើប្រាស់កម្រិតខ្ពស់៖ អេក្រង់ដែលបង្ហាញកូដ QR មានរូបតំណាងមួយដែលចែករំលែកលេខសុវត្ថិភាពនៅខាងលើផ្នែកខាងស្តាំ។ ការផ្ទៀងផ្ទាត់បុគ្គល ជាវិធីមួយ ប៉ុន្តែអ្នកប្រហែលជាបានផ្ទៀងផ្ទាត់លេខទំនាក់ទំនង ដោយប្រើប្រាស់កម្មវិធីសុវត្ថិភាពផ្សេង។ ដោយសារអ្នកបានផ្ទៀងផ្ទាត់លេខទំនាក់ទំនង អ្នកអាចទុកចិត្តកម្មវិធីក្នុងការផ្ទៀងផ្ទាត់លេខក្នុងស៊ីហ្គណល ដោយមិនចាប់មានក្នុងបញ្ជីទំនាក់ទំនង។ ក្នុងករណីនេះ អ្នកអាចចែករំលែកលេខសុវត្ថិភាពក្នុងកម្មវិធីនេះ ដោយចុច រូបតំណាង “ចែករំលែក” និងបញ្ជូនលេខសុវត្ថិភាពរបស់អ្នក។

## សារលុបចោលដោយខ្លួនឯង

ស៊ីហ្គណល មានមុខងារមួយដែលគេហៅថា «សារដែលលុបចោលដោយខ្លួនឯង» ដែលធានាថារាល់សារដែលជជែកក្នុងកិច្ចសន្ទនានឹងត្រូវបានលុបចោលពីទូរស័ព្ទ ឬកុំព្យូទ័រ របស់អ្នក និងដៃគូរសន្ទានារបស់អ្នកក្នុងរយៈពេលណាមួយបន្ទាប់ពីអ្នកបានអានសារទាំងនោះរួច ។ ដើម្បីដំណើរការមុខងារនេះ សូមអ្នកចូលទៅកាន់ប្រព័ន្ធ ស៊ីហ្គណល បន្ទាប់មកចុចលើកឈ្មោះដៃគូរសន្ទនារបស់អ្នកមួយណាដែលអ្នកចង់អោយសារនោះរលាយបាត់ក្រោយពេលអានរួច ។ សូមចុចលើសញ្ញាចុចៗ(រូបចុចៗ៣ នៅស្តាំដៃផ្នែកខាងលើអេក្រង់) ហើយសូមជ្រើសរើសយកពាក្យ ”សារដែលលុបចោលដោយខ្លួនឯង”




ផ្ទាំងថ្មីមួយ នឹងលោតឡើង ដើម្បីឲ្យអ្នកជ្រើសរើស ថាតើអ្នកចង់ឲ្យសាររលុបពេលណា។



បន្ទាប់ពីអ្នកជ្រើសរើសយកមុខងារនេះ អ្នកនឹងអាចឃើញនូវព័ត៌មាននៅក្នុងការសន្ទនាដែលបង្ហាញពី មុខងារ លុបសារ ត្រូវបានបើក។




ឥឡូវនេះអ្នកអាចផ្ញើសារដោយប្រាកដថាសារទាំងនោះនឹងត្រូវលុបចេញបន្ទាប់ពីរយៈពេលដែលអ្នកបានកំណត់។

## ការផ្លាស់ប្តូរទៅភាសាខ្មែរ

ដំបូង បើក ស៊ីហ្គណល។ នៅលើកអេក្រង់នេះ ចុចលើរូបតំណាង (រូបសញ្ញា ចុច៣ នៅជ្រុងខាងលើស្តាំដៃនៃអេក្រង់) ហើយជ្រើសរើសយក “ការកំណត់”។ ក្នុង “រូបរាង” ជ្រើសរើស “ភាសាខ្មែរ” ខាងក្រោម “ភាសា”។